ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤៨

ចុះថ្ងៃទី៨ - ៨ ២០០០

សាលដីកា

លេខ: ៣៨

ចុះថ្ងៃទី២៥ - ៧ - ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឃឹម ស៊ីផល ចៅក្រម

៣ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៤ - លោក ជីវ កេង ចៅក្រម

៥ - លោក ស៊ិន ឌឹម ចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី សុផុន សុមាធីកា

តំណាងមហាអយ្យការ

លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ០៧ ចុះថ្ងៃទី១១ - ០២ ២០០០ របស់ជនជាប់ចោទឈ្មោះអ៊ិន រី ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៤៣ ចុះថ្ងៃទី១១ - ០២ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ៤៨ ចុះថ្ងៃទី៨ - ៨ ២០០០ របស់ - តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះអ៊ិន រី " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុសអាយុ២២ឆ្នាំជាតិខ្មែរ កើតនៅភូមិឆ្លូក ឃុំចំការលើ ស្រុកស្ទោង ខេត្តកំពង់ធំ របររកស៊ីធ្វើយោធា ទីលំនៅមុនថ្ងៃចាប់ខ្លួននៅក្នុងបន្ទាយកងកាំភ្លើងធំលេខ១១២ ចំណុះយោធាភូមិភាគ៤ ឪពុកឈ្មោះលី អិន " ស " ម្តាយឈ្មោះជាប ទៀ " រ " ឃុំខ្លួនថ្ងៃទី០៦ - ១១ - ១៩៩៧ ។

ត្រូវចោទពីបទ : ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្នុងបន្ទាយយោធាភូមិភាគ៤ កាលពីថ្ងៃទី២៨ - ១០ - ៩៧ តាមមាត្រា៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មេធាវី កញ្ញា ឆយ ផល្លី

- ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះឈ្មោះឈុន សុភ័ណ្ឌ " ចុងបណ្តឹងសាទុក្ខ " ភេទស្រី អាយុ២៨ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃក្នុងបន្ទាយយោធាកងកាំភ្លើងធំលេខ១១២ ចំណុះភូមិភាគ៤ ក្នុងភូមិត្រគាត ឃុំស្លក្រាម ស្រុក-ខេត្តសៀមរាប ។

មេធាវី គ្មាន

- តាមកំណត់ហេតុយកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះថា : កាល

ពីថ្ងៃទី២៨ - ១០ - ៩៧ វេលាម៉ោង៤រសៀលឈ្មោះអ៊ិន រី បានចាញ់វះជាច្រើនគ្រាប់ចូលមក ក្នុងផ្ទះរបស់ខ្លួន ចំភ្លៅបណ្តាលអោយធ្លាក់ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់អយ្យការអមតុលាការខេត្តសៀមរាប ថា: ចោទលើឈ្មោះ អ៊ិន រី ពីបទ : ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្នុងបន្ទាយយោធា កាលពីថ្ងៃទី២៨ - ១០ - ៩៧ ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៣២ ចុះថ្ងៃទី១២ - ៥ - ៩៨ របស់តុលាការខេត្តសៀមរាប ដែលបានសំរេចថា :

១ - ផ្តន្ទាទោសឈ្មោះអ៊ិន រី ដាក់គុកកំណត់៦ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនពីបទ : ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្នុងបន្ទាយយោធាភូមិភាគ៤ កាលពីថ្ងៃទី២៨ - ១០ - ៩៧ តាមមាត្រា៣២ - ៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - វត្ថុតាងមានកាំភ្លើងអាកាមួយដើមលេខ ៩២៣៥ ត្រូវរឹបអូស និងប្រើប្រាស់ជាសម្បត្តិរដ្ឋ ។

៣ - អោយឈ្មោះអ៊ិន រី សងសំណងជម្ងឺចិត្តចំនួន៥០ម៉ឺនរៀលទៅអោយឈ្មោះ - ឈុន សុភ័ណ្ឌ ក្នុងករណីទណ្ឌិតខាងលើគ្មានប្រាក់សងត្រូវអនុវត្តតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយកំណត់៥០០ថ្ងៃ ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំហិតមុខដើម្បីប្តឹងវិស្សមកាលប្រឆាំងសំរេចប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី១៦ - ៦ - ១៩៩៨ របស់ឈ្មោះអ៊ិន រី ប្តឹងតវ៉ាពីសាលក្រមលេខ១៣២ ចុះថ្ងៃទី១២ - ៥ - ៩៨ របស់តុលាការខេត្តសៀមរាប លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: ផ្អែកតាមសាក្សីការចោទប្រកាន់នេះត្រឹមត្រូវហើយ សូមតុលាការតម្កល់សាលក្រមតុលាការខេត្ត - ទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៣ ចុះថ្ងៃទី១១ - ០២ ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦ - ៦ - ៩៨ របស់ឈ្មោះអ៊ិន រី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៣២ ចុះថ្ងៃទី១២ - ៥ - ៩៨ របស់តុលាការខេត្តសៀមរាបទុកជាបានការដដែលដោយគ្រាន់តែកែបទចោទប្រកាន់ចំណុចទី១ នៃសេចក្តីសំរេចពីបទ: មនុស្សឃាតដោយចេតនាមកបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា តាមមាត្រា៦៩ - ៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ

កំហុំងមុខដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ០៧ ចុះថ្ងៃទី១១-០២-២០០០ របស់ឈ្មោះអ៊ិន រី ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៤៣ ចុះថ្ងៃទី១១-០២-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១៥-០២-២០០១ របស់ឈ្មោះអ៊ិន រី ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសេចក្តីបញ្ជាក់ពីមូលហេតុ បានផ្លាស់ប្តូរទីលំនៅចេញពីបន្ទាយទាហាន មិនដឹងទៅរស់នៅទីណាទេ តាមការបញ្ជាក់ចុះថ្ងៃទី២៧-៣-២០០១ របស់សេនាធិការរង: សេនាតូចលេខ១២ ចំណុះយោធាភូមិភាគទី៤ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអម តុលាការកំពូលថា : មានពិរុទ្ធភាពលើឈ្មោះអ៊ិន រី ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាពិតប្រាកដមែន តម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- បានស្តាប់អំណានសារណារបស់ជនជាប់ចោទឈ្មោះអ៊ិន រី

- បានស្តាប់សេចក្តីបញ្ជាក់របស់សេនាធិការរង: សេនាតូចលេខ១២

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីកញ្ញា ឆយ ផល្លី ការពារអោយជនជាប់ចោទថា : កូនក្តីរបស់នាងខ្ញុំឈ្មោះអ៊ិន រី គឺគេគ្មានចេតនាបាញ់ទៅរកជនរងគ្រោះទេ គ្រាប់ដែលត្រូវជនរងគ្រោះ ជាគ្រាប់ផ្លាតទេ ។ នាងខ្ញុំសូមអោយតុលាការមេត្តាដោះលែង និងបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាសូមរក្សាសេចក្តីសន្និដ្ឋានដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ០៧ ចុះថ្ងៃទី១១ - ០២ ២០០០ របស់ជនជាប់ចោទ ឈ្មោះអ៊ិន វី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការលើកឡើងរបស់ជនជាប់ចោទក្នុងសារណាចុះថ្ងៃទី១៥ ០២ ២០០១ ថាខ្លួនគ្មានចេតនាបាញ់ទៅរកជនរងគ្រោះជាគ្រាប់ផ្លូត ដូច្នេះ សូមតុលាការមេត្តាដោះលែងខ្លួន នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថានៅចំពោះមុខតុលាការខេត្តសៀមរាប - ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនបានបាញ់ត្រូវជនរងគ្រោះប្រាកដមែន ។

- យល់ឃើញថាការដែលមេធាវីជនជាប់ចោទ សន្និដ្ឋានថាជនជាប់ចោទពុំបានប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាតាមមាត្រា៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទេ គប្បីផ្តន្ទាទោសពីបទបង្ករបួសស្នាមតាមមាត្រា៤១ វិញ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះជនជាប់ចោទបានបាញ់រះសំដៅផ្ទះជនរងគ្រោះតែម្តងធ្វើអោយជនរងគ្រោះស្ថិតនៅក្នុងផ្ទះនោះទទួលរងគ្រោះប៉ុន្តែមិនស្លាប់ដែលជាធាតុផ្សំនៃបទល្មើសប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាពិតប្រាកដ ។

- យល់ឃើញថាជនជាប់ចោទឈ្មោះ អ៊ិន វីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនផ្ញើមកតុលាការកំពូលរួចហើយ តែពុំបានមកចូលរួមសវនាការទេ ប៉ុន្តែមេធាវីរបស់ជនជាប់ចោទបានមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាតុលាការកំពូលបានបង្គាប់អោយដើមបណ្តឹងរដ្ឋប្បវេណីធ្វើសារណាឆ្លើយតប រួចហើយ ហើយក៏បានចេញដីកាកោះមកចូលរួមនាសវនាការនេះដែរ ប៉ុន្តែឈ្មោះនេះបានផ្លាស់ទីលំនៅទៅហើយពុំអាចរកឃើញទេ ដូច្នេះ តុលាការកំពូល ជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ

- យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ៤៣ ចុះថ្ងៃទី១១ - ០២-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១ - ទទួលបណ្តឹងសាទុក្ខលេខ០៧ ចុះថ្ងៃទី១១ - ០២ ២០០០ របស់ជនជាប់ចោទ ឈ្មោះអ៊ិន វី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៣ ចុះថ្ងៃទី១១ - ០២ ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុង ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៥ - ខែកក្កដា ឆ្នាំ ២០០១ ។